# របាយការណ៍សង្ខេបស្តីពីការវាយតម្លៃបឋមលើផលប៉ះពាល់
# នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង
# (មាត្រា ៥៖ កិច្ចព្រមព្រៀងខ្សែផ្តេកមិនស្របច្បាប់)

ច្បាប់ស្តីពីការប្រកួតប្រជែង ត្រូវបានកំណត់ជាលក្ខខណ្ឌតម្រូវសម្រាប់ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់ប្រទេសកម្ពុជា និងត្រូវបានដាក់ចូលក្នុងប្តេជ្ញាចិត្តរបស់សហគមសេដ្ឋកិច្ចអាស៊ាន ដែលតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជាត្រូវតែមានច្បាប់នេះ។ ដើម្បីសម្រេចឲ្យបាននូវការសន្យារបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន នាយកដ្ឋាននីតិកម្មនិងនាយកដ្ឋានកិច្ចការប្រកួតប្រជែងនៃក្រសួងពាណិជ្ជកម្មកម្ពុជា ជាអង្គភាពទទួលខុសត្រូវក្នុងការជំរុញដំណើរការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ឲ្យបានសម្រេចនិងមានប្រសិទ្ធិភាពខ្ពស់ស្របតាមគោលនយោបាយជាតិនិងអន្តរជាតិ ក្រោមជំនួយពីកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែង (Competition Law Implementation Program - CLIP) របស់គម្រោងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាង អាស៊ាន អូស្ត្រាលី និង ណូវែហ្សេឡង់ (ASEAN-Australia-New Zealand Free Trade Agreement - AANZFTA)។

សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងនេះ ផ្តោតសំខាន់លើផ្នែកចំនួន០៣ រួមមាន៖ (១).កិច្ចព្រមព្រៀងរារាំងការប្រកួតប្រជែង (កិច្ចព្រមព្រៀងខ្សែផ្តេកមិនស្របច្បាប់ ហៅកាត់ថា "កាតែល - Cartel" និងកិច្ចព្រមព្រៀងខ្សែឈរដែលមិនស្របច្បាប់) (២). ការរំលោភបំពានលើជំហរឧត្តមភាពលើទីផ្សារ (៣). ការរួមបញ្ចូលគ្នានៃធុរកិច្ច។ ដោយសារសកម្មភាពបំពានច្បាប់ប្រកួតប្រជែងភាគច្រើន កើតឡើងក្រោមរូបភាពជាកិច្ចព្រមព្រៀងខ្សែផ្តេកមិនស្របច្បាប់ (ការតែល) ដែលតម្រូវឲ្យស្ថាប័នប្រកួតប្រជែងត្រូវតែយកចិត្តទុកដាក់ខ្ពស់ អាស្រ័យហេតុនេះ យើងនឹងយកផ្នែកនេះមកធ្វើការវាយតម្លៃបឋម មុនផ្នែកផ្សេងៗទៀត។

**បញ្ហាប្រឈម៖** ដោយហេតុថា ប្រទេសកម្ពុជានៅមិនទាន់មានច្បាប់ស្តីពីការប្រកួតប្រជែងនិងស្ថាប័នគ្រប់គ្រងការប្រកួតប្រជែងនៅឡើយ ហេតុនេះហើយទាំងពាណិជ្ជករ អ្នកប្រើប្រាស់ឬអតិថិជនពុំមានការយល់ដឹងអំពីការប្រកួតប្រជែងដោយស្មើភាពនិងតម្លាភាពឡើយ។ ជាទូទៅ អ្នកប្រើប្រាស់ឬអតិថិជន ពុំមានភាពប្រាកដប្រជាថា តើទំនិញឬសេវាដែលខ្លួនបានទិញនៅលើទីផ្សារ ជាទំនិញឬសេវាដែលបានឆ្លងកាត់ការប្រកួតប្រជែងរវាងពាណិជ្ជករដែរឬទេ? ថាតើ តម្លៃ គុណភាព ឬបរិមាណទំនិញឬសេវាទាំងនោះត្រូវបានកំណត់ដោយទីផ្សារប្រកួតប្រជែង ឬត្រូវបានកំណត់ដោយ ពាណិជ្ជករណាម្នាក់ឬក្រុមពាណិជ្ជករណាមួយឬទេ? ក្នុងករណី តម្លៃ គុណភាព ឬបរិមាណទំនិញឬសេវាត្រូវបានកំណត់ដោយពាណិជ្ជករណាម្នាក់ឬក្រុមពាណិជ្ជករណាមួយនោះ ជាលទ្ធផល អ្នកប្រើប្រាស់ឬអតិថិជននឹងទទួលបាននូវទំនិញឬសេវាដែលមានតម្លៃខ្ពស់ គុណភាពទាប បរិមាណនិង ជម្រើសក៏តិច ហើយជាចុងក្រោយនឹងប៉ះពាល់ដល់សេដ្ឋកិច្ចជាតិទាំងមូល។

**គោលបំណង៖** សេចក្តីព្រាងច្បាប់នេះ ក៏ដូចជាមាត្រា ៥ និយាយជារួមមានគោលបំណង ជំរុញឲ្យមានការប្រកួតប្រជែងដោយតម្លាភាព ដើម្បីឲ្យអ្នកប្រើប្រាស់ឬអតិថិជនទទួលបានទំនិញឬសេវា មានតម្លៃថោក គុណភាពល្អ បរិមាណ ច្រើន និងជម្រើសច្រើន។ ទន្ទឹមនឹងនេះ ច្បាប់នេះ ក៏ចង់ ជំរុញឲ្យមានការបង្កើតនូវធុរៈកិច្ចថ្មីៗក្នុងទីផ្សារ ដែលនាំទៅរកការរីកចំរើនផ្នែកសេដ្ឋកិច្ចជាតិផងដែរ។

**ជម្រើស៖**

- **ជម្រើសទី១៖** គឺ **រក្សាស្ថានភាពដើម**
  (ពុំចាំបាច់មានសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ឬ មាត្រា៥៖ កិច្ចព្រមព្រៀងខ្សែផ្តេកដែលមិនស្របច្បាប់)
- **ជម្រើសទី២៖** គឺ **សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង**
  (មាត្រា៥៖ កិច្ចព្រមព្រៀងខ្សែផ្តេកដែលមិនស្របច្បាប់)

**ផលប៉ះពាល់៖** ច្បាប់ស្តីពីការប្រកួតប្រជែង (មាត្រា ៥) នឹងធ្វើឲ្យមានការផ្លាស់ប្តូរនូវទម្លាប់ឬ សកម្មភាពរបស់ពាណិជ្ជករក្នុងប្រទេសកម្ពុជាចំពោះការប្រកួតប្រជែងគ្នា ដែលជំរុញឲ្យងាកមករកនូវការប្រកួតប្រជែងគ្នាដោយស្មើភាពនិងតម្លាភាព ជាជាងការឃុបឃិតគ្នាដើម្បីកេងចំណេញផលប្រយោជន៍ពីអ្នកប្រើប្រាស់ឬអតិថិជន។ អាស្រ័យហេតុនេះ ច្បាប់នេះ (តាមរយៈមាត្រា៥) នឹងបង្កើតនូវកាតព្វកិច្ច លក្ខខណ្ឌតម្រូវ និង វិធានមួយចំនួនដែលពាណិជ្ជករត្រូវគោរពតាម ប៉ុន្តែវានឹងផ្តល់មកវិញនូវអត្ថប្រយោជន៍សម្រាប់រយៈពេលយូរអង្វែងដល់អ្នកប្រើប្រាស់ឬអតិថិជននិងសេដ្ឋកិច្ចជាតិទាំងមូល។

**កិច្ចពិគ្រោះយោបល់៖** ក្នុងអំឡុងពេលធ្វើការតាក់តែងសេចក្តីព្រាងច្បាប់នេះ ក្រសួងពាណិជ្ជកម្មធ្លាប់បានធ្វើសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ(ទាំងវិស័យសាធារណៈ និងវិស័យឯកជន) ចំនួនពីរលើក (លើកទី១ កាលពីឆ្នាំ២០១២ និងលើកទី២ កាលពីឆ្នាំ២០១៥) ជាលទ្ធផលភាគីពាក់ព័ន្ធទាំងអស់មានគាំទ្រយ៉ាងខ្លាំង និងស្មើ ជំរុញឲ្យមានការអនុម័តច្បាប់នេះក្នុងពេលឆាប់ស្របតាមលក្ខខណ្ឌតម្រូវរបស់ អាស៊ាន និង អង្គការពាណិជ្ជកម្មពិភពលោក។

**ការអនុវត្តន៍៖** ច្បាប់នេះ ពិសេសបញ្ញត្តិនៃមាត្រា៥ នឹងត្រូវអនុវត្តក្នុងរយៈពេល បី(០៣)ឆ្នាំ បន្ទាប់ពីច្បាប់នេះត្រូវបាន ប្រកាសដោយព្រះរាជក្រម។ ក្នុងគោលបំណងធានាឲ្យបាននូវការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ ច្បាប់នេះនឹង ផ្តល់ឱកាសឲ្យរាជរដ្ឋាភិបាលក្នុងការចេញ លិខិតបទដ្ឋានគតិយុត្តនានាដែលចាំបាច់សម្រាប់អនុវត្តច្បាប់នេះ។

# ការវាយតម្លៃបឋមលើផលប៉ះពាល់

| | | |
|---|---|---|
| ចំណងជើងបញ្ញត្តិកម្ម | ៖ | **សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង**<br>(**មាត្រា ៥៖ កិច្ចព្រមព្រៀងខ្សែរផ្តេកដែលមិនស្របច្បាប់**) |
| ក្រសួង | ៖ | ពាណិជ្ជកម្ម |
| លេខយោង | ៖ | ................................ |
| កាលបរិច្ឆេទចាប់ផ្តើម | ៖ | ១៣ កក្កដា ២០១៦ |
| កាលបរិច្ឆេទបញ្ចប់ | ៖ | ................................ |

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

ច្បាប់ស្តីពីការប្រកួតប្រជែង ត្រូវបានកំណត់ជាលក្ខខណ្ឌតម្រូវសម្រាប់ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់ប្រទេសកម្ពុជា និងត្រូវបានដាក់ចូលក្នុងប្តេជ្ញាចិត្តរបស់សហគមសេដ្ឋកិច្ចអាស៊ានដែលតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជាត្រូវតែមានច្បាប់នេះ។ ដើម្បីសម្រេចឲ្យបាននូវការសន្យារបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន នាយកដ្ឋាននីតិកម្មនិងនាយកដ្ឋានកិច្ចការប្រកួតប្រជែងនៃក្រសួងពាណិជ្ជកម្មកម្ពុជា ជាអង្គភាពទទួលខុសត្រូវក្នុងការ ជំរុញដំណើរការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងឲ្យបានសម្រេច និងមានប្រសិទ្ធិភាពខ្ពស់ស្របតាមគោលនយោបាយជាតិនិងអន្តរជាតិ ក្រោមជំនួយពីកម្មវិធីអនុវត្តច្បាប់ប្រកួតប្រជែង (Competition Law Implementation Program - CLIP) របស់គម្រោងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាង អាស៊ាន អូស្ត្រាលី និង ណូវែហ្សេឡង់ (ASEAN-Australia-New Zealand Free Trade Agreement - AANZFTA)។

សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងនេះ ផ្តោតសំខាន់លើផ្នែកចំនួន០៣ រួមមាន៖ (១).កិច្ចព្រមព្រៀងរារាំងការប្រកួតប្រជែង (កិច្ចព្រមព្រៀងខ្សែផ្តេកដែលមិនស្របច្បាប់ ហៅកាត់ថា "**កាតែល** - Cartel") និងកិច្ចព្រមព្រៀងខ្សែឈរដែលមិនស្របច្បាប់) (២).ការរំលោភបំពានលើជំហរឧត្តមភាពលើទីផ្សារ (៣).ការរួមបញ្ចូលគ្នានៃធុរកិច្ច។ ដោយសារសកម្មភាពបំពានច្បាប់ប្រកួតប្រជែងភាគច្រើន កើតឡើងក្រោមរូបភាពជាកិច្ចព្រមព្រៀងខ្សែផ្តេកដែលមិនស្របច្បាប់(ការតែល) ដែលតម្រូវឲ្យស្ថាប័នប្រកួតប្រជែងត្រូវតែយកចិត្តទុកដាក់ខ្ពស់ អាស្រ័យហេតុនេះយើងនឹងយកផ្នែកនេះមកធ្វើការវាយតម្លៃបឋម មុនផ្នែកផ្សេងៗទៀត។

កិច្ចព្រមព្រៀងខ្សែផ្តេកដែលមិនស្របច្បាប់ គឺ ស្ថិតក្នុងមាត្រា៥ នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ហើយមាត្រានេះមានគោលបំណងធ្វើការហាមឃាត់បុគ្គលទាំងឡាយ ក្នុងការធ្វើកិច្ចព្រមព្រៀងខ្សែផ្តេក (សំដៅដល់គូប្រកួតប្រជែងដែលស្ថិតក្នុងកម្រិតដូចគ្នា) ទាំងឡាយណាដែលមានកម្មវត្ថុឬអនុភាពលើ ៖

ក. ការកំណត់ថ្លៃឬការគ្រប់គ្រងថ្លៃទំនិញឬសេវាដោយផ្ទាល់ឬដោយប្រយោល

ខ. ការរារាំងឬការរិតត្បិតបរិមាណទំនិញឬសេវាដែលមានសម្រាប់លក់ ប្រភេទទំនិញឬសេវាដែលមានសម្រាប់លក់ ការអភិវឌ្ឍន៍ទំនិញឬសេវាថ្មី

គ. ការបែងចែកតំបន់ភូមិសាស្ត្ររវាងគូប្រកួតប្រជែង

ឃ. ការបែងចែកអតិថិជនរវាងគូប្រកួតប្រជែង

ង. ការដេញថ្លៃទាំងឡាយណាដែលមានទំនោរទៅរកអ្នកដេញថ្លៃតែមួយ ដើម្បីទទួលបានកិច្ចសន្យាដេញថ្លៃនោះ

ច. ការធ្វើពហិការមិនធ្វើប្រតិបត្តិការអាជីវកម្មជាមួយអ្នកផ្គត់ផ្គង់/អ្នកចែកចាយផ្សេងទៀត។

មាត្រា៥ នេះ នឹងធ្វើការហាមឃាត់បុគ្គលទាំងឡាយពីការធ្វើសកម្មភាពនានាដូចមានចែងក្នុងចំណុច (ក) ដល់ចំណុច (ច) ខាងលើ ប៉ុន្តែមាត្រានេះអាចត្រូវបានលើកលែងប្រសិនបើបុគ្គលនៃកិច្ចព្រមព្រៀងអាចអះអាងបានថា៖

- កិច្ចព្រមព្រៀងនោះ នឹងផ្តល់អត្ថប្រយោជន៍ច្រើនដល់សង្គម និងសេដ្ឋកិច្ច
- អត្ថប្រយោជន៍ដល់សង្គមនិងសេដ្ឋកិច្ចខាងលើ នឹងមិនអាចកើតឡើង ប្រសិនបើគ្មានកិច្ចព្រមព្រៀងនោនិង
- កិច្ចព្រមព្រៀងនេះមានអត្ថប្រយោជន៍ច្រើនជាងផលប៉ះពាល់ដែលកើតពីការប្រឆាំងការប្រកួតប្រជែង។

**ប្រភេទបញ្ញត្តិកម្ម៖**

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| ☑ | ☐ | ☐ | ☐ | ☐ | ☐ | ☐ |

**ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ៖**

☑ សេដ្ឋកិច្ច ☐សង្គមកិច្ច ☐បរិស្ថាន ☐.... ផ្សេងៗ

# ១. ការកំណត់បញ្ហា

## ១.១. បញ្ហាចម្បងដែលបញ្ញត្តិកម្មនេះមានបំណងដោះស្រាយ

### ក- បញ្ហាដល់ការប្រកួតប្រជែង៖

ការប្រកួតប្រជែងដោយស្មើភាពនិងមានតម្លាភាព នឹងជួយឲ្យអតិថិជនឬអ្នកប្រើប្រាស់ទទួលបាននូវទំនិញឬសេវាក្នុងតម្លៃទាប មានគុណភាពខ្ពស់ មានសម្បូរបែបនិងជម្រើសច្រើន។ ដោយនៅប្រទេសកម្ពុជាពុំទាន់មានច្បាប់ស្តីពីការប្រកួតប្រជែង និងស្ថាប័នគ្រប់គ្រងការប្រកួតប្រជែងនៅឡើយ ហេតុដូចនេះពាណិជ្ជករមួយចំនួន អាចបង្កើននូវប្រាក់ចំណេញរបស់ខ្លួនតាមវិធីមិនស្មោះត្រង់ ជាជាងការប្រកួតប្រជែងគ្នាដែលនាំឲ្យមានពាណិជ្ជករមួយចំនួនខាតឬត្រូវដើរចេញពីទីផ្សារ។ ពាណិជ្ជករទាំងនោះនឹងឃុបឃិតគ្នាធ្វើសកម្មភាពមិនស្របច្បាប់មួយចំនួនដូចជា ការឃុបឃិតគ្នាកំណត់តម្លៃទំនិញឬសេវាដូចគ្នា ការឃុបឃិតគ្នាបែងចែកតំបន់ភូមិសាស្ត្រ បែងចែកអតិថិជន និងកំណត់បរិមាណទំនិញឬសេវាលើទីផ្សារ និងការឃុបឃិតគ្នាក្នុងការដេញថ្លៃ ។ល។ ជាលទ្ធផលអតិថិជនឬអ្នកប្រើប្រាស់ជាអ្នករងផលប៉ះពាល់ពីសកម្មភាពទាំងនោះ ដូចជា ទំនិញឬសេវានៅលើទីផ្សារមានតម្លៃដូចគ្នា គុណភាពដូចគ្នា បរិមាណមានតិច ជម្រើសនៃទំនិញឬសេវាក៏មានតិចផងដែរ។ សកម្មភាពទាំងនេះ នឹងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចជាតិទាំងមូល។ ដោយយើងមិនទាន់មានច្បាប់និងស្ថាប័នសម្រាប់គ្រប់គ្រងការប្រកួតប្រជែង ជាហេតុនាំឲ្យអតិថិជនឬអ្នកប្រើប្រាស់ ខ្វះទំនុកចិត្តថា នៅពេលដែលខ្លួនបានទិញនូវទំនិញឬសេវាក្នុងតម្លៃណាមួយឬគុណភាពណាមួយនោះ តើតម្លៃឬគុណភាពរបស់ទំនិញឬសេវាទាំងនោះមានប្រកួតប្រជែងដែរឬទេ? ឬ តើតម្លៃឬគុណភាពរបស់ទំនិញឬសេវាទាំងនោះ ជាតម្លៃឬគុណភាពដែលបានកំណត់ដោយក្រុមពាណិជ្ជករណាមួយដែរឬទេ? អាស្រ័យហេតុនេះ បញ្ហាទាំងនេះរបស់អតិថិជនឬអ្នកប្រើប្រាស់ នឹងត្រូវបានដោះស្រាយ ប្រសិនបើយើងមានច្បាប់និងស្ថាប័នអនុវត្តច្បាប់ ដើម្បីដាក់ទោសទណ្ឌដល់ពាណិជ្ជករដែលបានបំពានច្បាប់នេះ។ ពាណិជ្ជករថ្មីៗ មិនហ៊ានចូលក្នុងទីផ្សារ ដោយខ្លាចនូវការប្រកួតប្រជែងខុសច្បាប់នានារបស់គូប្រកួតប្រជែងរបស់ខ្លួនក្នុងទីផ្សារនោះ និងមិនមានច្បាប់ការពារពួកគាត់។

### ខ. អនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ

លក្ខខណ្ឌដែលតម្រូវឲ្យមានច្បាប់ស្តីពីការប្រកួតប្រជែង ត្រូវបានកំណត់ក្នុងការចូលជាសមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organization - WTO) របស់រាជរដ្ឋាភិបាលកម្ពុជា និងត្រូវបានដាក់នៅក្នុងផែនការកំណត់របស់សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN) ដែលត្រូវអនុម័តច្បាប់ស្តីពីការប្រកួតប្រជែងឲ្យបានត្រឹមចុងឆ្នាំ២០១៦។

**គ. អនុលោមតាមច្បាប់ជាតិ**

ដោយយោងតាមមាត្រា៥៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឲ្យកម្ពុជាត្រូវអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ហើយដំណើរការនិងការរៀបចំប្រព័ន្ធសេដ្ឋកិច្ចនេះត្រូវកំណត់ដោយច្បាប់។ ច្បាប់ស្តីពីការប្រកួតប្រជែង គឺជាច្បាប់សំខាន់ដែលត្រូវបានគេប្រើប្រាស់សម្រាប់ដំណើរការប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។

ក្នុងការទាក់ទាញអ្នកវិនិយោគ ច្បាប់ស្តីការវិនិយោគនៅកម្ពុជា (មាត្រា ១០) បានកំណត់ថារាជរដ្ឋាភិបាលនឹងមិនធ្វើការគ្រប់គ្រងតម្លៃ ដែលផ្តល់លទ្ធភាពឲ្យអ្នកវិនិយោគកំណត់តម្លៃដោយឯករាជ្យស្របជាមួយលក្ខខណ្ឌប្រកួតប្រជែងទីផ្សារ ក្នុងនេះមានន័យថា តម្លៃត្រូវកំណត់ដោយទីផ្សារ ហើយគូប្រកួតប្រជែងអាចប្រកួតប្រជែងដោយស្មើភាពនិងតម្លាភាព ព្រោះគ្មានអន្តរាគមន៍ពីរាជរដ្ឋាភិបាលលើគូប្រកួតប្រជែងណាមួយឡើយ។ដោយការមានគាំទ្រពីរដ្ឋធម្មនុញ្ញជាតិ និងភាពស្របគ្នាជាមួយច្បាប់ស្តីពីការវិនិយោគនៅកម្ពុជា នឹងផ្តល់លទ្ធភាពងាយស្រួលក្នុងការជំរុញដំណើរការតាក់តែងសេចក្តីព្រាងច្បាប់នេះបានឆាប់រហ័ស។

### ១.២. បញ្ហាពាក់ព័ន្ធផ្សេងៗទៀតដែលបញ្ញត្តិកម្មនេះអាចជួយដោះស្រាយបានផងដែរ

- ជួយឲ្យអតិថិជនឬអ្នកប្រើប្រាស់ទទួលបាននូវទំនិញឬសេវា ដែលមានតម្លៃថោក មានគុណភាពខ្ពស់ មានបរិមាណច្រើន និងមានជម្រើសច្រើន។
- ទំនុកចិត្តកើនឡើងពីសំណាក់អតិថិជនឬអ្នកប្រើប្រាស់ ដោយសារមានច្បាប់នេះសម្រាប់ដាក់ទោសពិន័យដល់ពាណិជ្ជករដែលធ្វើការប្រកួតប្រជែងមិនស្របច្បាប់
- ជំរុញឲ្យមានពាណិជ្ជករថ្មីៗចូលរួមប្រកួតប្រជែងក្នុងទីផ្សារ ដោយសារពួកគេជឿជាក់ថាពួកគេត្រូវបានការពារពីគូប្រកួតប្រជែងនានាដែលបានប្រព្រឹត្តខុសពីច្បាប់ប្រកួតប្រជែង។

### ១.៣. សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ ប្រហែល។ ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនទាន់ គ្រប់គ្រាន់?

| |
|---|
| គ្មាន |

### ១.៤. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ? (ប្រសិនបើមាន សូមពន្យល់)

| |
|---|
| សំណើបញ្ញត្តិកម្មពុំមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងទេ |

## ២. គោលបំណង

មាត្រានេះ មានគោលបំណងដើម្បីជំរុញឲ្យមានការប្រកួតប្រជែងដោយស្មើភាពនិងតម្លាភាព ដើម្បីឲ្យអ្នកប្រើប្រាស់ឬអតិថិជនទទួលបានសេវានិងទំនិញមានតម្លៃថោក គុណភាពល្អ បរិមាណច្រើន និងជម្រើសច្រើន។ ទន្ទឹមនឹងនេះ ច្បាប់នេះ ក៏ចង់ជំរុញឲ្យមានការបង្កើតនូវធុរៈកិច្ចថ្មីៗក្នុងទីផ្សារ ដែលនាំទៅរកការរីកចម្រើនផ្នែកសេដ្ឋកិច្ចជាតិផងដែរ។

## ៣. ជម្រើស

- **ជម្រើសទី១៖ គឺ រក្សាស្ថានភាពដើម**
  (ពុំចាំបាច់មានសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង ឬ មាត្រា៥៖ កិច្ចព្រមព្រៀងខ្សែផ្តេកដែលមិនស្របច្បាប់)
- **ជម្រើសទី២៖ គឺ សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង**
  (មាត្រា៥៖ កិច្ចព្រមព្រៀងខ្សែផ្តេកដែលមិនស្របច្បាប់)

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាកិច្ច និងផលចំណេញ

### ៤.១. ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ រក្សាស្ថានភាពដើម | -ត្រូវរងបន្ទុកចំណាយលើការរៀបចំជំពូកផ្សេងទៀត (ក្រៅពីមាត្រា៥) ឬបញ្ញត្តិផ្សេងទៀតដែលអាចដោះស្រាយបញ្ហាបាន។<br>-ត្រូវប្រឈមមុខនឹងផលប៉ះពាល់ដែលអាចកើតឡើងពីការឃុបឃិតខ្សែផ្តេករវាងពាណិជ្ជករនៅក្នុងទីផ្សារ។ | -មិនមានរងបន្ទុកចំណាយអ្វីទាំងអស់ដោយសារទីផ្សារនៅរក្សាស្ថានភាពដើម។<br>-ភាគីដែលមិនបានចូលរួមក្នុងការឃុបឃិតអាចនឹងរងឥទ្ធិពលអវិជ្ជមានពីការឃុបឃិតខ្សែផ្តេករវាងពាណិជ្ជករនៅក្នុងទីផ្សារ។ |
| ជម្រើសទី២៖ សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង (មាត្រា ៥) | -បន្ទុកចំណាយក្នុងការរៀបចំសេចក្តីព្រាងច្បាប់។<br>-បន្ទុកចំណាយក្នុងការរៀបចំស្ថាប័នអនុវត្តច្បាប់ និងតាមដាន | -រងបន្ទុកចំណាយក្នុងការអនុវត្តន៍ច្បាប់ឲ្យបានត្រឹមត្រូវ។<br>-បន្ទុកចំណាយក្នុងការកែប្រែ រៀបចំឡើងវិញនូវស្ថានភាពអាជីវកម្ម |

| | | |
|---|---|---|
| | ទីផ្សារ។ | របស់ខ្លួនក្រោយពីមានការឃុប ឃិតកើតឡើងរួចហើយ។ |

## ៤.២. ការកំណត់ប្រភេទនៃផលចំណេញ

| **ជម្រើស** | **ប្រភេទនៃផលចំណេញ** |
|---|---|
| សំណើបញ្ញត្តិកម្ម | |
| ជម្រើសទី១៖<br>រក្សាស្ថានភាពដើម | -គ្មាន |
| ជម្រើសទី២៖ សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង<br>(មាត្រា ៥៖ កិច្ចព្រមព្រៀងខ្សែផ្តេកដែលមិនស្របច្បាប់) | -ទីផ្សារមានការប្រកួតប្រជែង នាំឲ្យមានកំណើនសេដ្ឋកិច្ច<br>-ជំរុញឲ្យមានការបង្កើតធុរកិច្ចថ្មីៗ និងគាំទ្រឲ្យមានទំនាក់ទំនងពាណិជ្ជកម្មដោយសមធម៌ និងមានប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ច<br>-ការប្រកួតប្រជែងដោយស្មើភាពគ្នានិងមានតម្លាភាព និងលើកទឹកចិត្តឲ្យមានការច្នៃប្រឌិតកាន់តែខ្ពស់<br>-បង្កើនទំនុកចិត្តដល់អ្នកប្រើប្រាស់ឬអតិថិជនលើទំនិញឬសេវាដែលពួកគាត់បានទិញឬប្រើប្រាស់ |

## ៤.៣. វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង /ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១៖<br>រក្សាស្ថានភាពដើម | -អ្នកប្រើប្រាស់ឬអតិថិជន<br>-សេដ្ឋកិច្ចជាតិ<br>-ក្រុមពាណិជ្ជករ ដែលមិនស្ថិតក្នុងកិច្ចព្រមព្រៀងខ្សែផ្តេក | គ្របដណ្តប់លើគ្រប់វិស័យធុរកិច្ច លើកលែងតែ | (មិនមានទិន្នន័យ) |

| | | | |
|---|---|---|---|
| | ដែលមិនស្របច្បាប់ | ក្រុមពាណិជ្ជករដែលឃុបឃិតខ្សែផ្គត់ផ្គង់នៅក្នុងទីផ្សារ។ | |
| ជម្រើសទី២៖សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង (មាត្រា ៥៖ កិច្ចព្រមព្រៀងខ្សែផ្គត់ដែលមិនស្របច្បាប់) | -ក្រុមពាណិជ្ជករដែលស្ថិតក្នុងកិច្ចព្រមព្រៀងខ្សែផ្គត់ដែលមិនស្របច្បាប់ | (មិនមានទិន្នន័យ ដោយសារមិនទាន់មានការស៊ើបអង្កេតឲ្យឃើញជាក់ស្តែង) | (មិនមានទិន្នន័យ ដោយសារមិនទាន់មានការស៊ើបអង្កេតឲ្យឃើញជាក់ស្តែង) |

## ៥. កិច្ចពិគ្រោះយោបល់

ក្នុងអំឡុងពេលធ្វើការតាក់តែងសេចក្តីព្រាងច្បាប់នេះ ក្រសួងពាណិជ្ជកម្មធ្លាប់បានធ្វើសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ(ទាំងវិស័យសាធារណៈ និងវិស័យឯកជន) ចំនួនពីរលើក (លើកទី១ កាលពីឆ្នាំ២០១២ និងលើកទី២ កាលពីឆ្នាំ២០១៥) ជាលទ្ធផលភាគីពាក់ព័ន្ធទាំងអស់មានគាំទ្រ យ៉ាងខ្លាំង និងស្នើជំរុញឲ្យមានការអនុម័តច្បាប់នេះក្នុងពេលឆាប់ស្របតាមលក្ខខណ្ឌតម្រូវរបស់ អាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក។

## ៦. សន្និដ្ឋាន

**តើចាំបាច់ត្រូវធ្វើការវាយតម្លៃពេញលេញ (RIS) ដែរឬទេ?**

☑**ចាំបាច់៖**

☐**មិនចាំបាច់៖**

## ៧. ការអនុវត្ត និងការតាមដានត្រួតពិនិត្យ

៧.១. តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អ ក្នុងអំឡុងពេលនៃការដាក់ឱ្យអនុវត្ត?

៧.២. តើគួរធ្វើការពិនិត្យតាមដានបញ្ញត្តិកម្មនេះឡើងវិញ ក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានដាក់ឱ្យអនុវត្តដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ ឬតាមដានយ៉ាងដូចម្តេច និងនៅពេលណា?

| ដំណើរការ | ឈ្មោះ | មុខងារ | ទំនាក់ទំនង |
|---|---|---|---|
| រៀបចំដោយ<br>ក្រុមRIA<br>ក្រសួងពាណិជ្ជកម្ម | ឯកឧត្ត ប៉ែន សុវិជាតិ<br>លោក ម៉េង សុឃាង<br>លោក សំ ចិត្រា | អគ្គនាយក និងជាប្រធាន RIA<br>សមាជិកRIA<br>សមាជិកRIA | ០១២ ៨១៦ ៦៦៣<br>០១២ ៩៩៣ ១៨៨<br>០៩៨ ២២៩ ៦៨៨ |
| ផ្តល់យោបល់ដោយ<br>ក្រុមRIA<br>របស់ECOSOCC៖ | ឯ.ឧ ប៊ិច សុខា | អ្នកគ្រប់គ្រងកម្មវិធីRIA | ០១២ ៦៩៨ ៩៩៩ |
| | ឯ.ឧ ឡោ ប៉ូលីណា | ប្រធានក្រុម១<br>ផ្នែកបណ្តុះបណ្តាល<br>និងសម្របសម្រួល | ០១២ ៧៨៨ ៦០៦ |
| | លោក អឹម រដ្ឋារ៉ា | សមាជិកក្រុម២ | ០១២ ៩៩៣ ៣៧០ |
| ជំនួយការ | កញ្ញា ឆេង គីមឡេង | បុគ្គលិករដ្ឋបាល | ០១៦ ៥១៥ ២៨៣ |
| បញ្ចូលទៅក្នុង<br>Database | | | |